ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

១៧/៧

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី
លេខៈ ៨១២
ចុះថ្ងៃទីៈ ១៧-០៥-២០១២
សាលក្រម
លេខៈ ៤៩ "ណ"
ចុះថ្ងៃទីៈ ០៥-១១-២០១២

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ លើសំណុំរឿងរដ្ឋប្បវេណីលេខ ៨១២ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២ ដោយមានសមាសភាពជំនុំជម្រះដូចតទៅៈ

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-រវាងដើមចោទឈ្មោះ [redacted] ផូ ភេទ ប្រុស អាយុ ៦២ ឆ្នាំ ជាតិខ្មែរ មុខរបររស៊ី បំរើកងហោះហើរដឹកជញ្ជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន មានទីលំនៅភូមិថ្មី ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ឃិន (ស) ម្តាយឈ្មោះ [redacted] ផុន (ស) ប្រពន្ធឈ្មោះ [redacted] វណ្ណថង មានកូន ០២ នាក់ ។

មេធាវីតំណាងដោយអាណត្តិលោក [redacted]

-ចុងចម្លើយឈ្មោះ [redacted] វណ្ណថង ភេទ ស្រី អាយុ ៦២ ឆ្នាំ ជាតិ ខ្មែរ របររកស៊ី មន្ត្រីចូលនិវត្តន៍ មានទីលំនៅផ្ទះលេខ D១ ភូមិ ៧ ក្រុម ២២ ផ្លូវលេខ ៩៧ សង្កាត់ បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ណាំ (ស) ម្តាយឈ្មោះ [redacted] ឡាញ់ (ស) ប្តីឈ្មោះ [redacted] ផូ មានកូន ០២ នាក់ ។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ

-<u>កម្មវត្ថុបណ្តឹងៈ</u>

១/-សុំលែងលះពីប្រពន្ធឈ្មោះ [redacted] វណ្ណថង

២/-សុំសិទ្ធិគ្រប់គ្រងគ្រប់គ្រងផ្ទះលេខ D១ ភូមិ ៧ ក្រុម ២២ ផ្លូវលេខ ៩៧ សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន រាជធានីភ្នំពេញ

ដាច់ទុក
26.11.2012
[redacted]

### អង្គហេតុ និងចំណុចទទាន

<u>១-សាលក្រមទាមទារដោយដើមចោទៈ</u>

-សុំលែងលះពីប្រពន្ធឈ្មោះ [redacted] វណ្ណថង

-សុំសិទ្ធិគ្រប់គ្រងគ្រប់គ្រងផ្ទះលេខ D១ ភូមិ ៧ ក្រុម ២២ ផ្លូវលេខ ៩៧ សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន រាជធានីភ្នំពេញ

<u>២-ការអះអាងរបស់គូភាគី</u>

ក-ការអះអាងរបស់ដើមចោទឈ្មោះ [redacted] ផូ ថា ខ្លួនមិនអាចរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធជាមួយឈ្មោះ [redacted] វណ្ណថង តទៅទៀតបានទេ គឺរក្សាជំហរប្តឹងសុំដូចក្នុងកម្មវត្ថុ

៣០៤

បណ្តឹងបន្ថែមចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១២ ដោយមូលហេតុរស់នៅមិនចុះសម្រុងគ្នា ខ្លួនបានបែកលំនៅសង្វាសតាំងពីឆ្នាំ ២០០៤ ។

✓ -ដើមចោទឈ្មោះ [redacted] បានថ្លែងការណ៍ថាៈ ខ្លួនរក្សាជំហរប្តឹងសុំលែងលះដដែល មិនអាចសះជាគ្នាវិញទេ ដោយមូលហេតុរស់នៅមិនចុះសម្រុងគ្នា ហើយមូលហេតុដែលនាំឲ្យខ្លួនអន់ចិត្តដោយសារប្រពន្ធខ្លួនមិនយកចិត្តទុកដាក់ជាមួយខ្លួន មិនជួយបោកសំលៀកបំពាក់ និយាយសម្តីមិនគួរសមដាក់ខ្លួន ហើយមានថ្ងៃមួយមានទំនាស់ជាមួយគ្នា ប្រពន្ធខ្លួនបានដណ្តើមយកកាំភ្លើងពីខ្លួន ហើយប្រមាថខ្លួនថា អញបាញ់ក្បាលឯងហើយថ្ងៃនោះដឹងឮដល់សមត្ថកិច្ចមូលដ្ឋានគេមកដកយកកាំភ្លើងព្រមទាំងធ្វើការសម្របសម្រួលទៀតផង ។ កាលដើមឡើយខ្លួនមានប្រពន្ធមុនឈ្មោះ [redacted] អូន បានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ តែប្រពន្ធមុនរបស់ខ្លួនបានទទួលមរណៈភាពកាលពីឆ្នាំ ២០០៤ ប្រពន្ធមុនគ្មានកូនទេ ។ ដំបូងឡើយខ្លួនបានរួមរស់ជាមួយចុងចម្លើយឈ្មោះ [redacted] ប៊ុនថង លក្ខណៈជាស្រីកំណាន់ប៉ុណ្ណោះ គឺរួមរស់ជាមួយគ្នាចាប់តាំងពីឆ្នាំ ១៩៨៧ មកម្លេះ លុះមកដល់ឆ្នាំ ២០០៤ ក្រោយពេលភរិយាមុនរបស់ខ្លួនស្លាប់ទៅ ចុងចម្លើយបាននាំកូនទាំងពីរនាក់មករស់នៅលើផ្ទះលេខ ០១ ផ្លូវលេខ ៩៧១ ភូមិ៧ ក្រុម២ សង្កាត់បឹងត្របែក ខណ្ឌ ចំការមន រាជធានីភ្នំពេញ ដោយគ្មានការអនុញ្ញាតិពីខ្លួនឡើយ ។

-រយៈកាលរួមរស់នៅជាមួយគ្នាជាមួយឈ្មោះ [redacted] វណ្ណថង មានកូនចំនួន ពីរនាក់ កូនទី១ឈ្មោះ [redacted] សោភ័ណ្ឌណារ៉ា ភេទស្រី កើតថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩៨ កូនទី២ ឈ្មោះ [redacted] សោភ័ណ្ឌរស្មី ភេទស្រី កើតថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩០ ដោយកូនទាំងពីរនាក់មានវ័យនីតិភាពអស់ហើយ ខ្លួនមិនទាមទារទេ ។

-សូមបញ្ជាក់ តុលាការឲ្យបានជ្រាបថា ចំពោះ ផ្ទះលេខ ០១ ផ្លូវលេខ ៩៧១ ភូមិ៧ ក្រុម២ សង្កាត់បឹងត្របែក ខណ្ឌ ចំការមន រាជធានីភ្នំពេញ គឺជាទ្រព្យសម្បត្តិដោយឡែករបស់ខ្លួននិងភរិយាមុន គឺមានវិញ្ញាបនប័ត្រ សំគាល់ម្ចាស់អចលនវត្ថុលេខ ១២០១១១០៧-០០៤៨ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១០ ដូច្នេះ ខ្លួនសុំសិទ្ធិគ្រប់គ្រងផ្ទះនេះជាកម្មសិទ្ធិផ្តាច់មុខ និងសុំឲ្យឈ្មោះ [redacted] វណ្ណថង ចេញពីផ្ទះរបស់ខ្លួន ។ ដោយចុងចម្លើយគាត់មានផ្ទះពីរទៀតអាចរស់នៅបានហើយ មានផ្ទះនៅសង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ផ្ទះនៅតាខ្មៅ ទទឹង៤ម៉ែត្រ បណ្តោយ៨ម៉ែត្រ សង់អំពីឈើ នៅលើដីបណ្តោយ ២៥ម៉ែត្រ និងដីមួយកន្លែងទំហំទទឹង ២០ម៉ែត្រ បណ្តោយ ២០ម៉ែត្រ ស្ថិតនៅភូមិព្រៃករាំង ឃុំកំពង់សំណាញ់ ស្រុកតាខ្មៅ ខេត្តកណ្តាល គឺជាទ្រព្យរួម ចំពោះទ្រព្យសម្បត្តិរួមទាំងនោះខ្លួនមិនទាមទារយកទេ ទ្រព្យរួមចំណែករបស់ខ្លួន ខ្លួនទុកឲ្យកូនទាំងពីរនាក់ ។

-ចំពោះការអះអាងរបស់ចុងចម្លើយថាប្រពន្ធមុនខ្លួនបាននិយាយជាមួយកូនៗនៅពេលប្រពន្ធមុនឈឺធ្ងន់ ថាទុកផ្ទះ ផ្ទះលេខ ០១ ផ្លូវលេខ ៩៧១ ភូមិ៧ ក្រុម២ សង្កាត់បឹងត្របែក ខណ្ឌ ចំការមន រាជធានីភ្នំពេញ ចែកឲ្យកូននោះជាពាក្យមិនពិតទេ ពីព្រោះកាលប្រពន្ធមុនឈឺធ្ងន់ កូនៗមិនមានមុខនៅជិតប្រពន្ធមុនខ្លួនទេ ។

-ចំពោះការចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយ តាមខ្លួនចាំគឺខ្លួនមិនបានទៅផ្តិតមេដៃចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគាត់ទេ មិនដឹងថាចុងចម្លើយគាត់ចុះរបៀបណា ខ្លួនទើបដឹងថាមានសំបុត្រអាពាហ៍ពិពាហ៍នៅពេលដែលគាត់យកសំបុត្រអាពាហ៍



Scanned with CamScanner

ពិពាហ៍មកបង្ហាញតុលាការនៅពេលខ្លួនប្ដឹងសុំឲ្យចុងចម្លើយចុះចេញពីផ្ទះ ។

-ខ្លួនមិនបានហៅចុងចម្លើយឲ្យមករស់នៅលើផ្ទះលេខ D១ ផ្លូវលេខ ៩៧១ ភូមិ៧ ក្រុម២ សង្កាត់បឹងត្របែក ខណ្ឌ ចំការមន រាជធានីភ្នំពេញ នោះទេ គឺចុងចម្លើយបានមករស់នៅលើផ្ទះលេខ D១ នេះដោយចិត្តគាត់ ហើយកាលនោះមិនទាន់មានទំនាស់ជាមួយគ្នា ក៏ចេះតែឲ្យគាត់រស់នៅលើផ្ទះលេខ D១ នោះទៅ ប៉ុន្តែពេលនេះខ្លួនរស់នៅមិនចុះសម្រុងគ្នា ហើយដោយខ្លួនជិតចូលនិវត្តន៍ត្រូវការយកផ្ទះ D១ មកគ្រប់គ្រងជាកម្មសិទ្ធិផ្ដាច់មុខ នឹងអាចចាត់ចែងជួលឲ្យគេ ដើម្បីបានប្រាក់កាសចាយវាយផ្ទាល់ខ្លួន ។

-ចំពោះការលើកឡើងរបស់ចុងចម្លើយថា គាត់បានចេញលុយជួសជុលផ្ទះលេខ D១ នោះ ខ្លួនធ្លាប់បានហាមគាត់មិនឲ្យធ្វើការជួសជុលដែរ តែគាត់មិនស្ដាប់ គាត់នៅតែធ្វើការជួសជុលផ្ទះលេខ D១ តាមចិត្តគាត់ ។ ចំពោះផ្ទះនៅបឹងកេងកងទី៣ ខ្លួនធ្លាប់បានឲ្យលុយទៅចុងចម្លើយចំនួនមួយតំឡឹងមាសទៅជួសជុលផ្ទះ ហើយចំពោះដីនៅតាខ្មៅ ខ្លួនធ្លាប់បានឲ្យលុយមួយតំឡឹងមាសនិងលុយដុល្លាសម្រាប់ចាក់ដី ។

ខ/-ការអះអាងរបស់ចុងចម្លើយឈ្មោះ [redacted] វណ្ណថង ថា: ចំពោះការប្ដឹងសុំលែងលះរបស់ដើមចោទ ខ្លួនមិនឯកភាពទេ ដោយខ្លួនចង់ឲ្យគាត់ផ្ដល់ភាពកក់ក្ដៅដល់កូន ឲ្យកូនមានឪពុកហៅនឹងគេ ។ ខ្លួនបានរស់នៅជាមួយគ្នាតាំងពីឆ្នាំ ១៩៨៧ រហូតមកទើបចុះសំបុត្រអាពាហ៍ពិពាហ៍ក្នុងឆ្នាំ ២០០៥ ។ រយៈកាលរួមរស់នៅជាមួយគ្នាមានកូនចំនួន ០២នាក់ ដូចដែលដើមចោទថ្លែងការណ៍ខាងលើមែន ។ ទ្រព្យសម្បត្តិរួមគ្មានទេ ចំពោះផ្ទះនៅបឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ និងផ្ទះនៅភូមិតាខ្មៅ ស្រុកតាខ្មៅ ព្រមទាំងដីមួយកន្លែងនៅភូមិកំពង់សំណាញ់គឺជាទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន ពីព្រោះលុយទាំងអស់សម្រាប់ទិញផ្ទះទាំងពីរនិងដីនោះគឺបានមកពីការលក់ផ្ទះគ្មានលេខ ផ្លូវកែវមុនី សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាផ្ទះកេរ្តិ៍របស់ឪពុកម្ដាយខ្លួនចែកឲ្យ ។ ចំពោះផ្ទះលេខ D១ ផ្លូវលេខ ៩៧ ក្រុម ២២ ភូមិ ៧ សង្កាត់បឹងត្របែក ខណ្ឌ ចំការមន រាជធានីភ្នំពេញ គឺពិតជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទជាមួយប្រពន្ធមុនរបស់គាត់មែន គឺខ្លួនជាអ្នកណែនាំជូនគាត់ទិញហើយខ្លួនជួយមើលថែរហូតមក ប៉ុន្តែប្រពន្ធមុនរបស់ដើមចោទ គាត់ថាទុកចែកឲ្យកូនឈ្មោះ [redacted] សោភ័ណ្ឌរស្មី តាមកូនខ្លួននិយាយប្រាប់ខ្លួនផ្ទាល់ ។ ខ្លួនស្រលាញ់រាប់អានប្រពន្ធមុនរបស់គាត់ទុកដូចបងស្រីដែរ ហើយនៅពេលប្រពន្ធមុនគាត់ស្លាប់ ដើមចោទបានហៅខ្លួនមកទាំងយប់មកជួយធ្វើបុណ្យសព ។ ដើមចោទបានចុះចោលខ្លួនតាំងពីឆ្នាំ ២០០៨ មកលេងខ្លួនម្ដងម្កាលប៉ុណ្ណោះ មិនដែលជួយផ្គត់ផ្គង់ចិញ្ចឹមកូនៗទេ គឺខ្លួនជាអ្នករកស៊ីចិញ្ចឹមកូនរហូតមក ពីមុនដើមចោទគាត់ស្រលាញ់ប្រពន្ធកូនណាស់ គាត់ចាប់ផ្ដើមកែប្រែចរិកចាប់ពីថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៨ រហូតមក ពេលគាត់ចូលផ្ទះសំលឹងមើលក្នុងក្រសែភ្នែកមិនធម្មតា ។ ចំពោះការទាមទាររបស់ដើមចោទ សុំយកផ្ទះលេខ D១ ផ្លូវលេខ ៩៧១ ភូមិ៧ ក្រុម២ សង្កាត់បឹងត្របែក ខណ្ឌ ចំការមន រាជធានីភ្នំពេញ ជាកម្មសិទ្ធិផ្ដាច់មុខ និងសុំឲ្យខ្លួនចុះចេញពីផ្ទះនោះខ្លួនមិនឯកភាពទេ ដោយហេតុថាដើមចោទជាអ្នកហៅខ្លួនឲ្យមករស់នៅលើផ្ទះនោះតាំងពីឆ្នាំ ២០០៤ នៅក្រោយពេលប្រពន្ធដើមរបស់គាត់ស្លាប់ ហើយខ្លួនបានចំណាយលុយជួសជុលផ្ទះនោះអស់ប្រាក់ប្រហែល ប្រាំ-ប្រាំមួយតំឡឹងមាសឯណោះ ម្យ៉ាងកាលប្រពន្ធដើមរបស់ដើមចោទនៅរស់ គាត់ស្រលាញ់កូនស្រីខ្លួនណាស់ ដោយគាត់គ្មានកូនបង្កើត ហើយយក

កូនខ្លួនមកចិញ្ចឹមតាំងពីតូច ប្រពន្ធដើមគាត់ធ្លាប់ប្រាប់កូនស្រីខ្លួនថា ទុកផ្ទះលេខ D១ នោះចែកឲ្យកូនស្រីខ្លួនហើយដើមចោទក៏ធ្លាប់និយាយដែរ ។

-ឈ្មោះ [redacted] សោភ័ណ្ឌណារ៉ា ជាកូនស្រីរបស់គូភាគីបានថ្លែងការណ៍ថា: ខ្លួនមានបងប្អូនបង្កើតពីរនាក់ ប្រពន្ធមុនប៉ារបស់ខ្លួនគាត់គ្មានកូនទេ ។ ប៉ាខ្លួនចុះចោលផ្ទះតាំងពីឆ្នាំ ២០០៨ មកម្លេះ គាត់កំរមកផ្ទះ គាត់ប្រាប់ម៉ាក់ថាគាត់រវល់ការងារ គាត់មិនដែលផ្គត់ផ្គង់ការរៀនសូត្រខ្លួនទេ ។ ប្រពន្ធមុនប៉ាគាត់យល់ព្រមឲ្យប៉ាយកម៉ាក់ខ្លួនធ្វើជាប្រពន្ធ ហើយកាលខ្លួននៅតូចៗខ្លួនធ្លាប់ឮម៉ាក់ធំ (ជាប្រពន្ធមុនប៉ាខ្លួន) បាននិយាយថាទុកផ្ទះលេខ D១ ផ្លូវលេខ ៩៧១ ភូមិ៧ ក្រុម២ សង្កាត់បឹងត្របែក ខណ្ឌ ចំការមន រាជធានីភ្នំពេញ ចែកឲ្យពួកខ្លួន ។ មូលហេតុប៉ាចុះចោលផ្ទះដោយគាត់មានស្រីថ្មីទៀត ពេលម៉ាក់ធំស្លាប់ខ្លួនមិនបានទៅទាន់ហេតុការណ៍ទេ ចំពោះការជួសជុលផ្ទះលេខ D១ នោះខ្លួនមិនដឹងថា ម៉ាក់ចំណាយប្រាក់អស់ប៉ុន្មានទេ ដឹងថាចំណាយអស់លុយច្រើន ។

-លោក [redacted] មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្ដីសន្និដ្ឋានថា: យោងតាមពាក្យបណ្ដឹងលើកទី១ និងពាក្យបណ្ដឹងបន្ថែម កូនក្ដីខ្ញុំនៅតែទទូចសុំឲ្យតុលាការសម្រេចសាលក្រមដូចការប្ដឹងទាមទាររបស់កូនក្ដីគឺទី១ សុំលែងលះពីប្រពន្ធដោយរស់នៅមិនចុះសម្រុងគ្នាយូរមកហើយ ។ ទី២ សុំសិទ្ធិគ្រប់គ្រងផ្ទះលេខ D១ ដែលជាទ្រព្យដោយឡែកដោយមានប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុលេខ ១២០១១១០៧-០០៤៨ ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១០ ដែលជាទ្រព្យសម្បត្តិដោយឡែករបស់កូនក្ដីខ្លួននិងប្រពន្ធឈ្មោះ [redacted] អូនឯទ្រព្យសម្បត្តិរួមដែលមានផ្សេងទៀត កូនក្ដីខ្ញុំមិនទាមទារយកទេ គឺសុំទុកឲ្យកូនទាំងពីរនាក់ ។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយបានធ្វើសេចក្ដីថ្លែងការណ៍ថា: ការប្ដឹងទាមទាររបស់ដើមដាប់ចោទសុំលែងលះ និងសុំទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទមិនសមហេតុផលទេ ។ ដោយហេតុថា ដើមចោទបានយកកូនក្ដីខ្លួនធ្វើជាប្រពន្ធតាំងពីឆ្នាំ ១៩៨៧ រហូតមានកូនស្រី ២នាក់ ហើយប្រពន្ធមុនរបស់ដើមចោទ គាត់បានយកកូនទាំងពីរទៅចិញ្ចឹមតាំងពីតូច ទើបផ្ដាច់ដោះទុកដូចកូនបង្កើតហើយប្រពន្ធមុនរបស់ដើមចោទធ្លាប់ប្រាប់កូនៗរបស់ចុងចម្លើយថាទុកផ្ទះលេខ D១ នោះចែកឲ្យពួកគេទាំងពីរនាក់ទៀតផង ។

ចំពោះការលើកឡើងរបស់ដើមចោទថាមិនបានហៅមិនបានអនុញ្ញាតិឲ្យកូនក្ដីខ្លួនមករស់នៅលើផ្ទះលេខ D១ មិនបានអនុញ្ញាតិឲ្យកូនក្ដីខ្លួនជួសជុលផ្ទះ នោះមិនសមហេតុផលទេ ដោយហេតុថាគូភាគីជាប្ដីប្រពន្ធ ទើបកូនក្ដីខ្លួនមានសិទ្ធិរស់នៅលើផ្ទះលេខ D១ ហើយដើមចោទបានគ្នាជាប្ដីប្រពន្ធរហូតមានកូនពីរនាក់ ។

ដើមចោទទទួលស្គាល់ថា មានការជួសជុលផ្ទះលេខ D១ នោះមែន ហើយគាត់បានប្ដឹងសមត្ថកិច្ចហាមមិនឲ្យកូនក្ដីខ្លួនធ្វើការជួសជុលផ្ទះលេខ D១ មិនសមហេតុផលទេ ។

ដើមចោទមិនដែលបានជួយទំនុកបំរុងកូនរៀនសូត្រទេ កូនក្ដីខ្លួនត្រូវការផ្ទះលេខ D១ សម្រាប់ឲ្យកូនរស់នៅបន្តទៀត ដោយសារផ្ទះពីរទៀតកូនក្ដីខ្លួនទុកសម្រាប់ជួលដើម្បីបានប្រាក់ផ្គត់ផ្គង់កូនរៀនសូត្រ ។

សុំឲ្យតុលាការច្រានចោលការប្ដឹងទាមទាររបស់ដើមចោទចោលជាអសាររបង់ និងសុំតុលាការសម្រេចឲ្យកូនក្ដីខ្លួនបានរស់នៅលើផ្ទះលេខ D១ បន្តទៀត ។



Scanned with CamScanner

៣-ការពន្យល់ត្រួសៗអំពីរឿងក្តី

៣.១-អង្គហេតុដែលជាមូលហេតុនៃការទាមទារ:

-ដើមចោទឈ្មោះ [redacted] ផូ និងចុងចម្លើយឈ្មោះ [redacted] វណ្ណថង បានរស់នៅជាមួយគ្នាតាំងពីឆ្នាំ១៩៨៧ រហូតដល់ឆ្នាំ២០០៥ ទើបបានចុះសំបុត្រអាពាហ៍ពិពាហ៍ ។ ក្នុងចំណងអាពាហ៍ពិពាហ៍នេះ គូភាគីមានកូនចំនួន ០២នាក់ ។ មូលហេតុដែលនាំឲ្យដើមបណ្តឹងប្តឹងលែងលះពីប្រពន្ធ ដោយមូលហេតុរស់នៅមិនចុះសម្រុងគ្នា ចុងចម្លើយមិនបំពេញកាតព្វកិច្ចជាប្រពន្ធ ថែមទាំងមានការប្រមាថមើលងាយ ដើមចោទនាំឲ្យអស់មនោសញ្ចេតនាពីគ្នា ។ ដើមចោទឈ្មោះ [redacted] ផូ សុំសិទ្ធិគ្រប់គ្រងផ្ទះដែលជាទ្រព្យដោយឡែកដោយមានប័ណ្ណសំគាល់ម្ចាស់អចលនវត្ថុលេខ ១២០១១១០៧-០០៤៨ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១០ ដែលជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទនិងប្រពន្ធមុនឈ្មោះ [redacted] អូន ចំណែកទ្រព្យសម្បត្តិរួមផ្សេងទៀតជាចំណែករបស់ដើមចោទ ដើមចោទសុំទុកឲ្យកូនទាំងពីរនាក់ស្មើៗគ្នា ។

## ចំណុចទាស់ក្នុងរឿងក្តី

-ក្នុងរឿងក្តីនេះ ឃើញថាមានចំណុចវិវាទ ដោយចុងចម្លើយមិនព្រមតាមការប្តឹងសុំលែងលះរបស់ដើមចោទនិងមិនព្រមចុះចេញពីផ្ទះលេខ D១ ផ្លូវលេខ ៩៧ ភូមិ៧ ក្រុម ២២ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ ។

-ចុងចម្លើយអះអាងថាបានចំណាយប្រាក់ខ្លះជួសជុលផ្ទះលេខ D១ ដើមចោទអះអាងថា មិនបានឲ្យចុងចម្លើយជួសជុលផ្ទះនោះទេ ប៉ុន្តែចុងចម្លើយនៅតែជួសជុលផ្ទះ ។

-បានឃើញ ពាក្យបណ្តឹងចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២ របស់ឈ្មោះ [redacted] ផូ ។

-បានឃើញ ពាក្យបណ្តឹងបន្ថែម ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១២ របស់ឈ្មោះ [redacted] ផូ ។

-បានឃើញ កំណត់ហេតុត្រៀមទាញហេតុផលលើកទី១ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១២ ។

-បានឃើញ កំណត់ហេតុត្រៀមទាញហេតុផលលើកទី២ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១២ ។

-បានឃើញ កំណត់ហេតុត្រៀមទាញហេតុផលលើកទី៣ ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១២ ។

-បានឃើញ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១២០១១១០៧-០០៤៨ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១០ ។

-បានឃើញ ពាក្យសុំបញ្ចូលភស្តុតាង ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០១២ របស់លោក [redacted] ជាមេធាវី តំណាងដោយអាណត្តិរបស់ចុងចម្លើយ ។

## សំអាងហេតុ

១-ដើមចោទឈ្មោះ [redacted] ផូ និងចុងចម្លើយឈ្មោះ [redacted] វណ្ណថង ពិតជាប្តីប្រពន្ធនឹងគ្នាហើយ បានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់មានសំបុត្រអាពាហ៍ពិពាហ៍តាម

លិខិតលេខ ៧៥ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៥ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងកេងកង៣ ។

២-តាមមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី តម្រូវឲ្យភាគីនារីស្ថិតក្នុងភាពមេម៉ាយ ចំនួន ១២០ ថ្ងៃ គិតពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយឬលុបចោល ។

៣-ដើមចោទអះអាងថា: ការរស់នៅមិនចុះសំរុងគ្នាដោយមានភាពរកាំរកូសនឹងគ្នានិងអស់មនោសញ្ចេតនាពីគ្នា ខ្លួនមិនអាចសះជារស់នៅជាមួយគ្នាតទៅទៀតបាន ។ ហើយដើមចោទនិងចុងចម្លើយបានបែកលំនៅសង្វាសពីគ្នារយៈតាំងពីឆ្នាំ ២០០៨ មក ហើយ ដូច្នេះការទាមទាររបស់ដើមចោទមានលក្ខណៈសមហេតុផលអាចឲ្យតុលាការពិនិត្យសម្រេចបានយោងតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ។

៤-ដើមចោទនិងចុងចម្លើយក្រោយពីរួមរស់ជាមួយគ្នាមានកូនចំនួន០២នាក់ឈ្មោះ [redacted] សោភ័ណ្ឌណារ៉ា ភេទស្រី កើតថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៨ និងឈ្មោះ [redacted] សោភ័ណ្ឌរស្មី ភេទស្រី កើតថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៦ ឃើញថា មានវ័យនីតិភាពអស់ហើយ ជាពិសេសគូភាគី ក៏មិនបានទាមទារដែរ ដូច្នេះ តុលាការមិនចាំបាច់ពិចារណាសម្រេចទេ ។

៥-ដើមចោទអះអាងថា ទ្រព្យសម្បត្តិរួមមានផ្ទះនៅសង្កាត់បឹងកេងកង៣ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១២០១០៤០៥-០១១៤ ធ្វើនៅរាជធានីភ្នំពេញ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០០៧ និងផ្ទះនៅតាខ្មៅ ទំហំទទឹង ៤ម៉ែត្រ x បណ្តោយ ៨ម៉ែត្រ សង់អំពីឈើ នៅលើដីប្រវែង ២៥ម៉ែត្រ និងដីមួយកន្លែងបណ្តោយ ២០ម៉ែត្រ ទទឹង ២០ម៉ែត្រ ស្ថិតនៅភូមិព្រៃករាំង ឃុំកំពង់សំណាញ់ ស្រុកតាខ្មៅ ខេត្តកណ្តាល ដើមចោទមិនទាមទារយកទេ រីឯភាគីចុងចម្លើយបានអះអាងថា ទ្រព្យសម្បត្តិទាំងអស់ខាងលើនេះគឺជាទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន ចំណុចនេះគ្មានវិវាទនឹងគ្នាទេ ដូច្នេះតុលាការពុំលើកយកមកពិនិត្យពិចារណាសម្រេចឡើយ ។

៦-វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១២០១១១០៧-០០៤៨ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១០ ស្ថិតនៅទីតាំងផ្ទះលេខ D១ ភូមិ៧ ក្រុម២២ ផ្លូវលេខ ៩៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ជាទ្រព្យដោយឡែករបស់ឈ្មោះ [redacted] ផុ និងប្រពន្ធមុនដែលបានទទួលមរណៈភាពឈ្មោះ [redacted] អូន មិនមែនជាទ្រព្យសម្បត្តិរួមជាមួយឈ្មោះ [redacted] ផុ និងឈ្មោះ [redacted] វណ្ណថង ឡើយ ដូច្នេះដើមចោទទាមទារមានលក្ខណៈត្រឹមត្រូវ យោងតាមមាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណី ។

៧-តាមសេចក្តីថ្លែងការណ៍របស់គូភាគីឃើញថាភាគីចុងចម្លើយពិតជាបានចំណាយប្រាក់ខ្លួនដើម្បីជួសជុលផ្ទះលេខ D១ មែន តែការជួសជុលនេះ គឺដើម្បីរស់នៅទាំងអស់គ្នា ដូច្នេះការដែលចុងចម្លើយមិនព្រមចុះចេញពីផ្ទះលេខ D១ នោះគឺពុំត្រូវឡើយ ម្យ៉ាងទៀតតាមការអះអាងរបស់ដើមចោទបញ្ជាក់ថាខ្លួនក៏បានផ្តល់ប្រាក់មួយចំនួនឲ្យចុងចម្លើយជួសជុលផ្ទះនៅសង្កាត់បឹងកេងកង៣និងជួសជុលផ្ទះនៅតាខ្មៅដែរ ចាត់ទុកថាគូភាគីបានជួសជុលផ្ទះឲ្យគ្នាទៅវិញទៅមក ។

៨-គូភាគីអះអាងថា ពុំមានជំពាក់បំណុលគេទេ ដូច្នេះតុលាការពុំលើកយកចំណុចនេះមកពិចារណាឡើយ ។

៩-ដើមចោទឈ្មោះ [redacted] ផូ ត្រូវទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដី យោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ហេតុដូច្នេះសម្រេច

១/-ឲ្យដើមចោទឈ្មោះ [redacted] ផូ និងចុងចម្លើយឈ្មោះ [redacted] វណ្ណថង ផ្ដាច់សមគ្គសង្វាសពីគ្នា យោងតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ។

២/-ឲ្យឈ្មោះ [redacted] វណ្ណថង ស្ថិតក្នុងភាពមេម៉ាយចំនួន ១២០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសាលក្រមនេះតទៅ យោងតាមមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី ។

៣/-ទ្រព្យសម្បត្តិដោយឡែករួមមាន ផ្ទះលេខ D១ មានទីតាំងស្ថិតនៅភូមិ ៧ ក្រុម ២២ ផ្លូវ ៩៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១២០១១១០៧-០០៤៨ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១០ ប្រគល់ឲ្យទៅដើមចោទឈ្មោះ [redacted] ផូ គ្រប់គ្រងជាកម្មសិទ្ធិផ្ដាច់មុខ យោងតាមមាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណី ។

៤/-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ ។

៥/-សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

បានឃើញ
ចៅក្រមជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២
ក្រឡាបញ្ជី

[redacted]

- បានទទួល
ថ្ងៃទី០3-12-2012

[redacted]





Scanned with CamScanner